# រឿង ពពាល ឆ្កែល្អ



ឆ្នាំ ២០១០

អ្នកនិពន្ធ : លោកស្រី តឹក ស៊ីផុន
: លោកស្រី យឹម ចាន់ស្រី
អ្នករៀបរៀង : លោកស្រី ហួត សេយ៉ោន
វិចិត្រករ : លោក ឯម សត្យា

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ សេចក្ដីសម្រេចលេខ ១៣៨ អរ.សសរ.
ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩០ ដើម្បីប្រើប្រាស់នៅតាមសាលារៀនមត្តេយ្យ

**គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ**

បោះពុម្ពលើកទី១ ចំនួន៥,០០០ក្បាល
រោងពុម្ពក្រសួងអប់រំ ឆ្នាំ១៩៩១

**អំណោយ អ៊ុយនីសេហ្វ**
DON DE L'UNICEF

បោះពុម្ពលើកទី២ដោយ : អង្គការគាំពារកុមារខ្មែរ (CYK)

ភ្នំពេញ ខែកក្កដា ឆ្នាំ២០១០

មូលនិធិ : ប្រាក់សន្សំរបស់អ្នកចូលរួមទាំងអស់នៅប្រៃសណីយ៍ជប៉ុនសម្រាប់ជំនួយស្ម័គ្រចិត្តអន្តរជាតិ

ចំនួន : ៥,០០០ក្បាល

លេខ : CYK N10012

រោងពុម្ព : **J S R C** Printing House



ពពាលជាកូនឆ្កែមួយមានរោមវែងៗ ទន់ពណ៌សលាយខ្មៅមួយដុំៗ។ នារីស្រឡាញ់ពពាលណាស់ ព្រោះពពាលជាកូនឆ្កែក្លាហាន ចេះជួយបំពេញភារកិច្ចជានិច្ច។

ល្ងាចថ្ងៃអាទិត្យមួយ នៅពេលដែលនារីកំពុងប្រឡែងជាមួយពពាលដោយរីករាយ ស្រាប់តែនាងនឹកចង់ហៅសុភីជាមិត្តឱ្យមកលេងជាមួយ។



ភ្លាមនោះនារីស្ទុះទៅសរសេរសំបុត្រ
មួយ។ ចំណែកពពាលអង្គុយសម្លឹងមុខ
ម្ចាស់ធ្វើភ្នែកម៉ក់ៗ បក់កន្ទុយរវិចៗ រង់ចាំទទួលបញ្ជា។



សរសេរចប់នារីបត់សំបុត្រ ច្រកចូលក្នុងស្រោម ការខ្នង
ថា៖ "ជូនចំពោះសុភី" រួចនិយាយទៅកាន់ពពាលថា៖
"ពពាលឯងជាមិត្តដ៏ល្អរបស់ខ្ញុំមែនទេ? នេះនែសំបុត្រ!
ឯងត្រូវពាំនាំយកទៅឱ្យសុភីជាមិត្តយើងឮទេ?"



រ៉ូស! រ៉ូស! ពពាលបក់កន្ទុយរវិចៗជាសញ្ញាយល់ព្រម។ បន្ទាប់មកពពាលក៏ពាំនាំយកសំបុត្ររត់យ៉ាងលឿនសំដៅទៅផ្ទះសុភី។



ល្ងាចនេះមេឃស្រឡះល្អណាស់។ តាមផ្លូវពពាលឃើញកូនឆ្កែ កូនឆ្មាជាច្រើនកំពុងរត់ប្រដេញគ្នាលេង លើវាលស្មៅយ៉ាងសប្បាយ ផ្កាក្រហមមួយទងឱនក្បាលគួរសមនឹងពពាល ហើយនិយាយថា៖

"សួស្តីមិត្តពពាល! ចូលរួមចំណែករត់លេងជាមួយយើងសិនឬទេ?"

ពពាលនឹកចង់លេងដែរ។ ប៉ុន្តែពពាលនឹកឃើញថាខ្លួនត្រូវនាំសំបុត្រទៅឱ្យសុភីសិន។

ពពាលឆ្លើយ៖ "អរគុណណាស់បងផ្កា! ខ្ញុំជាប់រវល់បន្តិច"។ មកដល់ផ្សារក្លិនសាច់គោអាំងយ៉ាងឈ្ងុយហើរមកប៉ះច្រមុះ។ ពពាលនឹកចង់ហូបសាច់គោអាំងណាស់ វាឈរទ្រឹងនឹកក្នុងចិត្តថា៖



"បើខ្ញុំហូបសាច់នេះ ខ្ញុំត្រូវទម្លាក់សំបុត្រចោល ហើយខ្យល់អាចបើងសំបុត្រហើរទៅបាត់"។ បងនារីច្បាស់ជាខឹងនឹងខ្ញុំហើយ។ គិតដូចនេះហើយពពាលក៏រត់យ៉ាងក្លាហានសំដៅទៅផ្ទះបងសុភី។



មិនយូរប៉ុន្មានពពាលក៏មកដល់ផ្ទះសុភី។ ពពាលហត់ណាស់។ សុភីឃើញដូចនេះ ក៏ទទួលសំបុត្រយកមកអាន ហើយឱបពពាលដោយពោលថា៖

"ចាំខ្ញុំយកស៊ុបមកឱ្យញ៉ាំ"



ពេលចប់សុភីក៏យកស៊ុបឆ្អឹងគោមួយចានធំជារង្វាន់ដល់ពពាល។ ពពាលសប្បាយចិត្តណាស់ដោយបានបំពេញកិច្ចការឱ្យម្ចាស់បានជោគជ័យ។



ទាំងពីរនាក់ ពពាលនិងសុភី នាំគ្នាដើរយ៉ាងលឿនសំដៅមកផ្ទះនារីវិញ ដោយរីករាយក្រៃលែង។

ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋានអប់រំកុមារតូច

CYK

This aid project is supported by all participants in Japan's Postal Saving for International Voluntary Aid.
និងអង្គការគាំពារកុមារខ្មែរ ( CYK )

9789996317088